# របាយការណ៍ប្រចាំឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

ក្នុងឆ្នាំ ២០១៥ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. **ស្ថានភាពមន្ត្រីរាជការ÷**

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សរុបចំនួន ៣១ នាក់ ស្ត្រី ០៤ នាក់ និងដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០២ រូប ។

2. **សកម្មភាពថ្នាក់ដឹកនាំមន្ទីរ÷**

- ចូលរួមប្រជុំបូកសរុបលទ្ធផលការងាររបស់រដ្ឋបាលសាលាខេត្តក្រចេះ នៅសាលប្រជុំសាលាខេត្ត ប្រចាំឆ្នាំ ២០១៤ និងទិសដៅឆ្នាំ ២០១៥
  - ប្រចាំខែមករានៅថ្ងៃទី០៥/០១/២០១៥
  - ប្រចាំខែកុម្ភៈនៅថ្ងៃទី១៣/០២/២០១៥
  - ប្រចាំខែមីនានៅថ្ងៃទី០៩/០៣/២០១៥
  - ប្រចាំខែត្រីមាសនៅថ្ងៃទី០៩/០៤/២០១៥
  - ប្រចាំខែឧសភានៅថ្ងៃទី០៨/០៥/២០១៥
  - ប្រចាំឆមាសទី១ ថ្ងៃទី១៣/០៧/២០១៥
  - ប្រចាំខែកក្កដាឆ្នាំ២០១៥ថ្ងៃទី១១/០៨/២០១៥
  - ប្រចាំខែសីហាថ្ងៃទី១០/០៩/២០១៥
  - ប្រចាំត្រីមាសទី៣ថ្ងៃទី២៣/១០/២០១៥
  - ប្រចាំខែតុលាថ្ងៃទី១៧/១១/២០១៥
- ចូលរួមប្រជុំពិភាក្សាដោះស្រាយស្ថានភាពខេត្ត ដើម្បីរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត (២០១៥-២០១៩) ថ្ងៃទី០៨/០១/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមក្នុងពិធីសម្ពោធអាគារសិក្សានៅគរុកោសល្យខេត្ត ថ្ងៃទី១៤/០១/២០១៥ និងសមិទ្ធផលនានាក្នុងវត្តពោធិព្រឹក្ស ភូមិឈើទាលភ្លោះ នៅថ្ងៃទី០៦/០៣/២០១៥
- ចូលរួមប្រជុំពិភាក្សាការងារលទ្ធកម្មឆ្នាំ២០១៥ នៅថ្ងៃទី១៩/០១/២០១៥
- ចូលរួមប្រជុំត្រៀមរៀបចំបុណ្យទន្លេ នៅថ្ងៃទី១៩/០១/២០១៥នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រកាសតែងតាំង÷
  - ប្រធានរតនាគារខេត្ត នៅថ្ងៃទី១៣/០១/២០១៥
  - នាយខណ្ឌរដ្ឋបាលព្រៃឈើខេត្ត និងប្រធានមន្ទីរសង្គមកិច្ច ថ្ងៃទី១២/០២/២០១៥
  - ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ថ្ងៃទី១៦/០២/២០១៥
  - ប្រធានបរិស្ថានខេត្តថ្ងៃទី០៦/១០/២០១៥

- ប្រធានសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ថ្ងៃទី១៦/០២/២០១៥

- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារត្រីមាសទី៤ ឆ្នាំ២០១៤ របស់គណៈកម្មការនាយកមូលនិធិសមធម៌នៅមន្ទីរពេទ្យបង្អែកឆ្លូង ថ្ងៃទី២៦/០១/២០១៥ និងមន្ទីរពេទ្យបង្អែកខេត្ត នៅថ្ងៃទី២៧/០១/២០១៥
- ចូលរួមសន្និបាតបូកសរុបការងារឆ្នាំ២០១៤ និងលើកទិសដៅឆ្នាំ២០១៥ មាន÷
  - មន្ទីរអប់រំយុវជន និងកីឡាខេត្តថ្ងៃទី២៣/០១/២០១៥នៅសាលមហោស្រពខេត្តក្រចេះ
  - រដ្ឋបាលខេត្តក្រចេះ ថ្ងៃទី១០-១១/០២/២០១៥នៅសាលមហោស្រពខេត្តក្រចេះ
  - ក្រសួងអភិវឌ្ឍន៍ជនបទ នៅថ្ងៃទី១២/០២/២០១៥ នៅសាលសន្និសិទចតុមុខភ្នំពេញ
- ចូលរួមកិច្ចប្រជុំសាមញ្ញរបស់ គ.ក.ស.ក ក្រុមប្រឹក្សាខេត្ត បាន ០៣ លើក ថ្ងៃទី២៣/០១/២០១៥ និងថ្ងៃទី១៦/០៣/២០១៥ និងនៅថ្ងៃទី០៥/០៦/២០១៥
- ចូលរួមប្រជុំប្រចាំឆ្នាំស្តីពីកម្មវិធីផែនការ សុវត្ថិភាពទឹកផឹកជនបទ និងពិនិត្យប្លង់បច្ចេកទេសដំបូងតម្លៃប៉ាន់ស្មានផ្លូវកៅស៊ូ ២ ជាន់ និងសំណង់ដែលក្រុមហ៊ុនបានចុះកិច្ចសន្យានៅរាជធានីភ្នំពេញ នៅថ្ងៃទី២៩/០១/២០១៥
- ចូលរួមប្រជុំបើក និងពិនិត្យវាយតម្លៃឯកសារដេញថ្លៃផ្លូវថែទាំ ឆ្នាំ២០១៥សម្រាប់កម្មវិធី RIPIII នៅថ្ងៃទី០៥/០២/២០១៥ នៅភ្នំពេញ
- ចូលរួមក្នុងពិធីបើកការប្រកួតកីឡាសិស្ស ថ្ងៃទី០៦/០២/២០១៥ និងបិទនៅថ្ងៃ១២/០២/២០១៥ នៅពហុកីឡាដ្ឋានខេត្ត
- ចូលរួមប្រគល់វិញ្ញាបនបត្រសម្គាល់អចលវត្ថុនៅឃុំដំរីផុង ស្រុកឆ្លូង ថ្ងៃទី២៣/០២/២០១៥
- ចូលរួមប្រជុំក្រុមការងារគណៈកម្មការបុណ្យទន្លេ ថ្ងៃទី២១/០២/២០១៥ នៅសាលាខេត្ត
- ចូលរួមក្នុងពិធីផ្សព្វផ្សាយធ្វើពលកម្មសម្អាតទីក្រុង ថ្ងៃទី០២/០៣/២០១៥ នៅសាលមហោស្រពខេត្ត
- ចូលរួមទិវានារីអន្តរជាតិ ៨ មីនា ២០១៥ ថ្ងៃទី០៥/០៣/២០១៥ នៅសាលមហោស្រពខេត្ត
- ចូលរួមវេទិកាវប្បធម៌ជាតិ ៣ មីនា ថ្ងៃទី១០/០៣/២០១៥ នៅសាលមហោស្រពខេត្ត
- ចូលរួមប្រជុំត្រួតពិនិត្យការងារត្រៀមរៀបចំពិធីបុណ្យទន្លេ ថ្ងៃទី១១/០៣/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមដាំកូនឈើនៅសហគមន៍ ភូមិកោះទ្រង់ សង្កាត់កោះទ្រង់ នៅថ្ងៃទី១២/០៣/២០១៥
- ចូលរួមក្នុងពិធីបុណ្យទន្លេ នៅថ្ងៃទី១៣/០៣/២០១៥
- ចូលរួមកិច្ចប្រជុំសាមញ្ញលើកទី១០ ១១ ១២ អាណត្តិទី២ ឆ្នាំទី១របស់ក្រុមប្រឹក្សាខេត្តនៅថ្ងៃទី១៨/០៣/២០១៥, ២១/០៤/២០១៥ និងថ្ងៃទី២១/០៥/២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមក្នុងពិធីបិទការិយាល័យរបស់អង្គការ Oxfam នៅថ្ងៃទី១៩/០៣/២០១៥ សណ្ឋាគារ ហ៊ារ ប៊ុន្នី
- ចូលរួមសម្អាតច្រាំងទន្លេនៅថ្ងៃទី១៩/០៣/២០១៥
- ចូលរួមទស្សនកិច្ចសិក្សាគម្រោងអាហារសម្រាប់ជីវិតនៅភូមិស្អាត ឃុំស្រែចារ ស្រុកស្នួល នៅថ្ងៃទី១២/០៣/២០១៥ Sarmaritans Purrse
- ចូលរួមប្រគល់ទទួលបញ្ចប់សុពលភាពការងារជួសជុល ៧៣ អណ្តូងមានៈ

- ស្រុកស្អាង ៦៨ អណ្តូង
- ស្រុកចិត្របុរី ៥ អណ្តូង

- ចូលរួមប្រជុំស្តីពីការអនុវត្តការងាររបស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្ងៃទី២៥/០៣/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំពិគ្រោះយោបល់សម្រាប់គម្រោង ធ្វើអាជីវកម្មរ៉ែលោហៈរបស់ក្រុមហ៊ុន KHOV PRIMSEC CO,LTD នៅថ្ងៃទី២៧/០៣/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីសម្ពោធ ឆ្លងសមិទ្ធផលនានានៅវត្តតាម៉ៅ ឃុំតាម៉ៅស្រុកព្រែកប្រសព្វ នៅថ្ងៃទី២៨/០៣/២០១៥ និងនៅវត្តមញ្ជាសិលាថ្មគ្រែឃុំថ្មគ្រែ ស្រុកចិត្របុរី ថ្ងៃទី២៩/០៣/២០១៥
- ចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ ថ្ងៃទី៣០/០៣/២០១៥ នៅសាលប្រជុំមន្ទីរអប់រំខេត្ត
- ចូលរួមសូត្រមន្តឆ្លងចូលឆ្នាំមមែសប្តស័ក ព.ស ២៥៥៩ និងបំពាក់គ្រឿងឥស្សរិយយសការងារប្រគល់លិខិតសរសើរប័ណ្ណសរសើរដល់មន្ត្រីរាជការនៅថ្ងៃទី០៣/០៤/២០១៥ នៅសាលមហោស្រពខេត្ត
- ចូលរួមក្នុងពិធី សម្ពោធឆ្លងឧបដ្ឋានសាលានៅវត្តពោធិសត្ថារ៉ាមហៅហុងឡាំ សង្កាត់អូរឬស្សីក្រុងក្រចេះ ថ្ងៃទី ០៤/០៤/២០១៥
- ចូលរួមប្រជុំគណៈកម្មការនាយកមូលនិធិសមធម៌ ប្រចាំត្រីមាសទី១ ឆ្នាំ២០១៥ នៅមន្ទីរពេទ្យបង្អែកឆ្លូង ថ្ងៃទី ០៩/០៤/២០១៥ និងមន្ទីរពេទ្យបង្អែកខេត្តនៅថ្ងៃទី១០/០៤/២០១៥
- ចូលរួមប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាខេត្ត ថ្ងៃទី១០/០៤/២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីសម្ពោធ ឆ្លងសមិទ្ធផលនានា នៅវត្តមុនីសាគរ ឃុំពង្រស្រុកឆ្លូង ថ្ងៃទី១១/០៤/២០១៥ និងបានឧបត្ថម្ភបុណ្យចំនួន២០$(ម្ភៃដុលាអាមេរិក)
- ចូលរួមចែករង្វាន់ដល់សិស្សពូកែក្នុងខេត្ត នៅថ្ងៃទី២០/០៤/២០១៥ ក្នុងនោះមន្ទីរបានឧបត្ថម្ភជាថវិកាចំនួន ៥០០០០៛ (ហាសិបពាន់រៀល) និងសិស្សទទួលជ័យលាភីនិទ្ទេស A B C នៅថ្ងៃទី១៨/០៨/២០១៥
- ចូលរួមជាគណៈអធិបតីក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមាវត្តសមិទ្ធិរាម នៅថ្ងៃទី២៥/០៤/២០១៥ ភូមិអូរគ្រៀង ឃុំអូរគ្រៀង ស្រុកសំបូរ
- ចូលរួមប្រជុំពិភាក្សាវាយតម្លៃស្តីពីការតែងតាំងមន្ត្រីរាជការនៅថ្ងៃទី២៩/០៤/២០១៥ សាលប្រជុំសាលាខេត្ត
- ចូលរួមសន្និបាទបូកសរុបការងារសុខាភិបាលខេត្ត នៅថ្ងៃទី០៤/០៥/២០១៥ មន្ទីរសុខាភិបាលខេត្ត
- ចូលរួមសិក្ខាសាលាថ្នាក់ខេត្ត ស្តីពីការផ្សព្វផ្សាយបច្ចុប្បន្នកម្មទិន្នន័យគ្រួសារក្រីក្រ ២០១៥ នៅថ្ងៃទី០៥/០៥/២០១៥ នៅមន្ទីរផែនការ
- ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសផ្ទេរមុខតំណែង មេបញ្ជាការកងរាជអាវុធហត្ថខេត្ត នៅថ្ងៃទី ០៧/០៥/២០១៥ បញ្ជាការដ្ឋានខេត្ត
- ចូលរួមពិធីប្រគល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុភូមិប្រម៉ា នៅថ្ងៃទី០៨/០៥/២០១៥ នៅវត្តឧត្តមសាមគ្គី ភូមិវាលកន្សែង

- ចូលរួមពិធីបញ្ចុះខណ្ឌសីមាវត្តស្វាយចេក នៅថ្ងៃទី១០/០៥/២០១៥
- ចូលរួមពិធីសូត្រមន្តចម្រើនព្រះជន្មព្រះករុណា ព្រះបាទសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា គម្រប់ ព្រះជន្ម ៦២ ចូល ៦៣ ព្រះវស្សា នៅថ្ងៃទី១១/០៥/២០១៥ សាលមហោស្រព
- ចូលរួមប្រជុំពិគ្រោះយោបល់ក្រុមហ៊ុន ដុង ណាយ នៅថ្ងៃទី១៩/០៥/២០១៥ សាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំស្តីពីផលប៉ះពាល់របស់ ក្រុមហ៊ុន ដុង ណាយ នៅថ្ងៃទី២០/០៥/២០១៥ សាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំក្រុមហ៊ុន ឈុន ហុង នៅថ្ងៃទី២០/០៥/២០១៥ សាលប្រជុំសាលាខេត្ត
- ចូលរួមស្តាប់ការប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីតាម Video Conference នៅថ្ងៃទី២២/០៥/២០១៥ សាល Video Conference សាលាខេត្ត
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយថ្នាក់ខេត្តស្តីពីការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលសម្រេចបាន ដល់ប៉ះពាល់ក្រោមកម្មវិធីពង្រឹងសមាហរណកម្ម នៅថ្ងៃទី២៨/០៥/២០១៥ នៅស្រុកបានលុងខេត្តរតនគិរី
- ចូលរួមវេទិកាសាធារណៈចំនួន ៤៨ ដង
- ចូលរួមប្រជុំបណ្តាញយេនឌ័រថ្នាក់ខេត្ត នៅថ្ងៃទី២៩/០៥/២០១៥ នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី
- ចូលរួមភ្ញៀវកិត្តិយសក្នុងពិធីចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ នៅថ្ងៃទី០៣/០៦/២០១៥ ខណ្ឌរដ្ឋបាលព្រៃឈើ
- ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ផ្លូវការ បន្ទប់រង់ចាំសម្រាលកូន នៅថ្ងៃទី០៤/៦/២០១៥ នៅមណ្ឌលសុខភាពថ្មគ្រែ
- ចូលរួមភ្ញៀវកិត្តិយសក្នុងសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលសម្រេចបាន របស់គម្រោងភាពធន់ទៅនឹង ការប្រែប្រួលអាកាសធាតុ នៅថ្ងៃទី០៤/០៦/២០១៥
- ចូលរួមប្រជុំជាមួយប្រតិភូក្រសួងបរិស្ថាន នៅថ្ងៃទី០៤/០៦/២០១៥សាលាខេត្ត
- ចូលរួមប្រជុំចរចាថ្លៃលើការងារថែទាំផ្លូវជាលក្ខណៈខួប ចំនួន ១៤ គម្រោង នៅថ្ងៃទី០៥/០៦/២០១៥ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមប្រជុំបើកសំណើដេញថ្លៃគម្រោង ចំនួន ០៤ គម្រោង សម្រាប់ឆ្នាំ ២០១៥ នៅថ្ងៃទី០៥/០៦/២០១៥ សាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំជាមួយគណៈកម្មាធិការទី០៦នៃព្រឹទ្ធសភា នៅថ្ងៃទី១០/០៦/២០១៥សាលាប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមកិច្ចប្រជុំពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ០៥ ឆ្នាំ ២០១៥-២០១៩ ថ្ងៃទី១១/០៦/២០១៥ សាលាប្រជុំសាលាខេត្ត
- ចូលរួមវាយតម្លៃប្រគល់ទទួលទំនិញ ០៤ គម្រោង សម្រាប់ឆ្នាំ២០១៥ នៅថ្ងៃទី១១/០៦/២០១៥ សាលប្រជុំសាលាខេត្ត
- ចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីប្រារព្ធខួបលើកទី៨ ទិវាអតីតយុទ្ធជនកម្ពុជា ២១ មិថុនា ឆ្នាំ២០១៥ នៅថ្ងៃទី១២/០៦/២០១៥

- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី ការប្រើប្រាស់ឯកសារព័ត៌មានស្ថានភាព និងឯកសារព័ត៌មានពិន្ទុវិស័យ កសាងកម្មវិធីវិនិយោគឃុំ នៅថ្ងៃទី១៧/០៦/២០១៥ មន្ទីរផែនការ
- ចូលរួមជាគណៈអធិបតីក្នុងពិធីសម្ពោធព្រះវិហារ និងសមិទ្ធផលក្នុងវត្តក្រចេះ នៅថ្ងៃទី១៨/០៦/២០១៥
- ចូលរួមប្រជុំបើកសំណើដេញថ្លៃ ០៣ ដង
- ចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យ (JTWG-ED) ថ្ងៃទី២៩/០៦/២០១៥ នៅសាលប្រជុំ មន្ទីរអប់រំយុវជន និងកីឡា
- ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់វិញ្ញាបនបត្របញ្ចាក់ការសិក្សាជូនមន្ត្រី ថ្ងៃទី២៩/០៦/២០១៥ នៅសាល មហោស្រពខេត្ត
- ចូលរួមប្រជុំពិភាក្សាស្តីពីការត្រួតពិនិត្យការប្រើប្រាស់ដី និងការជ្រើសរើសមុខសញ្ញាអ្នកទទួលដីសម្បទាន សង្គមកិច្ច ថ្ងៃទី២៦/០៦/២០១៥ នៅសាលប្រជុំផ.អ.៣
- ចូលរួមប្រជុំពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងផែនការឆ្នាំ ថ្ងៃទី ១៩-២០/០៧/២០១៥ សាលប្រជុំសាលា ខេត្ត
- ចូលរួមប្រជុំពិភាក្សាស្តីពីការរៀបចំផែនការថវិកាឆ្នាំ ២០១៦ ថ្ងៃទី០២/០៧/២០១៥ នៅក្រសួងអភិវឌ្ឍន៍ ជនបទ
- ចូលរួមកិច្ចប្រជុំណែនាំ ស្តីពីការរៀបចំសំណើគម្រោងវិនិយោគបីឆ្នាំរំកិល ២០១៥-២០១៧ ថ្ងៃទី ០៣/០៧/ ២០១៥ នៅសាលប្រជុំមន្ទីរផែនការ
- ចូលរួមប្រជុំពិភាក្សាអំពីការបំពេញការងាររបស់មន្ត្រីរាជការ ថ្ងៃទី០៣/០៧/២០១៥ ក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមស្តាប់ការប្រជុំគណៈរដ្ឋមន្ត្រី តាម (Video Conference) ថ្ងៃទី១០/០៧/២០១៥ នៅសាលប្រជុំសាលា ខេត្ត
- ចូលរួមពិធីរុក្ខទិវាថ្នាក់ខេត្ត ថ្ងៃទី១៣/០៧/២០១៥ នៅឃុំឃ្សឹម ស្រុកស្នួល
- ចូលរួមកិច្ចប្រជុំសាមញ្ញរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី ថ្ងៃទី ២២/០៧/២០១៥ នៅសាល ប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយច្បាប់ផ្លូវថ្នល់ ថ្ងៃទី២២/០៧/២០១៥ នៅសាលមហោស្រពខេត្ត
- ចូលរួមប្រជុំសាមញ្ញបានចំនួន ០២ លើក អាណត្តិទី ២ ឆ្នាំទី ២ របស់ក្រុមប្រឹក្សាខេត្ត ថ្ងៃទី២៣/០៧ ២០១៥ និងថ្ងៃទី២០/០៨/២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមកម្មវិធីវិនិយោគឃុំបុសលាវ ថ្ងៃទី៣០/០៧/២០១៥ នៅសាលាឃុំបុសលាវ
- ចូលរួមប្រជុំវិសាមញ្ញលើកទី ១១ អាណត្តិទី២ ឆ្នាំទី២ របស់ក្រុមប្រឹក្សាខេត្ត ថ្ងៃទី៣០/០៧/២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមវគ្គបណ្តុះបណ្តាលមន្ត្រីជួរមុខគណៈកម្មាធិការជួញដូរមនុស្ស នៅថ្ងៃទី០៦-០៧/០៨/២០១៥ នៅ សាលប្រជុំសាលាខេត្ត

- ចូលរួមប្រជុំពិភាក្សាអំពីឡូត៍ដីជូនមុខសញ្ញាទទួលដីឃុំដារ និងឃុំចំបក់ ថ្ងៃទី១០/០៨/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមវាយតម្លៃប្រគល់ទទួលការផ្គត់ផ្គង់សម្ភារ និងបរិក្ខាបច្ចេកទេស ថ្ងៃទី១៣/០៨/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រកាសតែងតាំងប្រធានមន្ទីរធម្មការ និងសាសនា ថ្ងៃទី១៧/០៨/២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមប្រជុំពិគ្រោះយោបល់ ស្តីពីលទ្ធផលនៃការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម ថ្ងៃទី១៨/០៨/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមពិនិត្យវាស់វែង និងសិក្សាផលប៉ះពាល់ដីរបស់ប្រជាពលរដ្ឋនៅក្នុងក្រុមហ៊ុន ស្ថិតនៅឃុំឃ្សឹម ស្រុកស្នួល ថ្ងៃទី១៩-២៩/០៨/២០១៥
- ចូលរួមពិនិត្យ និងសិក្សាពីស្ថានភាពប្រើប្រាស់ដី ក្នុងបរិវេណដីសម្បទានសង្គមកិច្ច ឃុំថ្មគ្រែ ថ្ងៃទី២១/០៨/២០១៥ នៅឃុំថ្មគ្រែ
- ចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីបញ្ចុះបឋមសិលា សាងសង់អគារសិក្សាវិទ្យាល័យថ្មគ្រែ ថ្ងៃទី២១/០៨/២០១៥ នៅឃុំថ្មគ្រែ
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងកម្មវិធីសម្ពោធអគារសិក្សាថ្មរាប ថ្ងៃទី២២/០៨/២០១៥ នៅភូមិថ្មរាប
- ចូលរួមសិក្សាផ្សព្វផ្សាយ ស្តីពី ការផ្តើមអនុវត្តកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មី ថ្ងៃទី០១/០៩/២០១៥ នៅសណ្ឋាគារ លីជី
- ចូលរួមពិនិត្យវាយតម្លៃប្រគល់ទទួល ការផ្គត់ផ្គង់សម្ភារការិយាល័យ ជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ ថ្ងៃទី០២/០៩/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំពិភាក្សាថ្នាក់ក្រោមជាតិ លើសេចក្តីព្រាងយុទ្ធសាស្ត្ររេដបូកកម្ពុជា ថ្ងៃទី០៨-០៩/០៩/២០១៥ នៅសណ្ឋាគារលីជី
- ចូលរួមបើកសិក្ខាសាលាស្តីពីសេចក្តីសន្និដ្ឋាន ៥២ ចំណុច លើរបាយការណ៍ជាតិលើកទី៤ និងទី៥ អនុសញ្ញាលុបបំបាត់ការរើសអើងប្រឆាំងនឹងនារីថ្ងៃទី១៤/០៩/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមសិក្ខាសាលា ស្តីពី ការវាយតម្លៃលទ្ធផលសម្រេចបាន គោលដៅអភិវឌ្ឍន៍សហស្សវត្សន៍កម្ពុជា ២០១៣-២០១៥ ថ្ងៃទី១៨/០៩/២០១៥ នៅសណ្ឋាគារ ៧ មករា ខេត្តកំពង់ចាម
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីប្រារព្ធទិវាអក្ខរកម្មជាតិ ០៨/០៩/២០១៥ ថ្ងៃទី១៦/០៩/២០១៥ ឃុំស្វាយជ្រះ
- ចូលរួមប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី ការទប់ស្កាត់យានយន្តដឹកលើសទម្ងន់បើកបរលើផ្លូវជនបទ ថ្ងៃទី១៦/០៩/២០១៥ នៅរាជធានីភ្នំពេញ
- ចូលរួមសិក្ខាសាលាចែករំលែកបទពិសោធន៍របស់អង្គការ CHOBA និងអង្គការ WASHOBAថ្ងៃទី២២/០៩/២០១៥ នៅខេត្តកំពង់ចាម
- ចូលរួមសិក្ខាសាលាបញ្ចប់គម្រោង បញ្ញាបយេនឌ័រ ថ្ងៃទី០៨/០៩/២០១៥ នៅសណ្ឋាគារភ្នំពេញ

- ចូលរួមសិក្ខាសាលា ស្តីពីគម្រោងលើកកម្ពស់សន្តិសុខស្បៀងតាមសហគមន៍ជនបទ និងទីប្រជុំជនរណប ថ្ងៃទី១៧ កញ្ញា ឆ្នាំ២០១៥ នៅសាលប្រជុំផអ៣
- ចូលរួមកិច្ចប្រជុំសាមញ្ញលើកទី១៦, ១៧ អណត្តិទី២ ឆ្នាំទី២ របស់ក្រុមប្រឹក្សាខេត្ត បានចំនួន ០២លើក នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមប្រជុំផ្សព្វផ្សាយពីលទ្ធផលទិន្នផលក្នុងស្រុកសរុបបឋម GDP ថ្ងៃទី២១ កញ្ញា ២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំពិភាក្សាក្រុមប្រឹក្សាជាតិដើម្បីស្ត្រី ពីការអនុវត្ត CEDAW អនុសាសន៍សម្តេចតេជោ ច្បាប់ពាក់ព័ន្ធនឹងការលើកកម្ពស់ស្ត្រី ថ្ងៃទី២៩ កញ្ញា ២០១៥ សាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំអង្គការសង្គមស៊ីវិលស្តីពីទំនាស់ដីធ្លី ធនធានធម្មជាតិ និងកិច្ចសុំអន្តរាគមន៍ពីអាជ្ញាធរ ថ្ងៃទី ២៣ កញ្ញា ២០១៥ សាលប្រជុំសាលាខេត្ត
- ចូលរួមវេនកាន់បិណ្ឌ នៅវត្តប៉ាឆា ថ្ងៃទី២៧ កញ្ញា ២០១៥
- ចូលរួមបើកការដ្ឋានសាងសង់សកលវិទ្យាល័យខេត្តក្រចេះ ថ្ងៃទី២៦ កញ្ញា ២០១៥ នៅ សង្កាត់អូរឫស្សី ក្រុងក្រចេះ
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា នៅវត្តភ្នំសុពណ៌កាឡី ថ្ងៃទី២៥ កញ្ញា ២០១៥
- ចូលរួមកាន់បិណ្ឌ នៅវត្តក្រគរ ថ្ងៃទី ០២ តុលា ២០១៥
- ចូលរួមពិធីសំណេះសំណាល សួរសុខទុក្ខ លោកគ្រូ អ្នកគ្រូ ថ្ងៃទី០២ តុលា ២០១៥ នៅវិទ្យាល័យព្រះ កុសុម:
- ចូលរួមជាអធិបតីក្នុងពិធីមិទ្ទិញ ទិវាមនុស្សចាស់ ថ្ងៃ០១ តុលា ២០១៥ នៅសាលមហោស្រព
- ចូលរួមពិធីប្រកាសមុខតំណែងថ្មីរបស់មន្ទីរបរិស្ថាន ថ្ងៃទី០៦ តុលា ២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមប្រជុំផ្សព្វផ្សាយពីដំណើរការរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សថ្ងៃទី០៦ តុលា ២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីប្រកាសសមាសភាពថ្នាក់ដឹកនាំសមាគមអតីតយុទ្ធជនកម្ពុជា ថ្ងៃទី០៧ តុលា ២០១៥ នៅសាលមហោស្រពខេត្ត
- ចូលរួមទិវាទេសចរណ៍ពិភពលោក ថ្ងៃទី០៨ តុលា ២០១៥ នៅសាលមហោស្រពខេត្ត
- ចូលរួមប្រជុំប្រកាសការវាស់វែង និងចុះបញ្ជីដីរដ្ឋ ថ្ងៃទី០៨ តុលា ២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមគោរពវិញ្ញាណក្ខន្ធព្រះករុណា ព្រះមហាវីរៈក្សត្រ ថ្ងៃទី ១៦ តុលា ២០១៥ នៅសាលមហោស្រពខេត្តក្រចេះ
- ចូលរួមប្រជុំពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ថ្ងៃទី២០ តុលា ២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្តក្រចេះ
- ចូលរួមដេញថ្លៃផ្លូវជនបទ ថ្ងៃទី១៩ តុលា ២០១៥ នៅសាលប្រជុំសាលាខេត្ត

- ចូលរួមកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើគម្រោងកម្មវិធីវិនិយោគទាំងបីប្រភេទថ្ងៃទី២២ តុលា ២០១៥ នៅសាលប្រជុំនៃមន្ទីរផែនការ
- ចូលរួមពិធីសំណេះសំណាល និងស្វាគមន៍គណៈប្រតិភូក្រុង Rizhao ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ នៅសាលប្រជុំខេត្តក្រចេះ
- ចូលរួមប្រជុំបណ្តាញយេនឌ័រថ្នាក់ខេត្ត ថ្ងៃទី២៧ តុលា ឆ្នាំ២០១៥ នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីថ្នាក់ខេត្ត
- ចូលរួមវេទិកាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ស្តីពីសិទ្ធិទទួលព័ត៌មានវិស័យអប់រំនៅមូលដ្ឋានសហគមន៍ ថ្ងៃទី២៧ តុលា ឆ្នាំ២០១៥
- ចូលរួមប្រជុំពង្រឹងគណៈកម្មាធិការប្រយុទ្ធជំងឺគ្រុនចាញ់ប្រចាំត្រីមាសទី៤ ឆ្នាំ ២០១៥ ថ្ងៃទី៣០ តុលា ២០១៥ សាលប្រជុំមន្ទីរសុខាភិបាលខេត្តក្រចេះ
- ចូលរួមប្រជុំបូកសរុបវេទិកាសាធារណៈ ថ្ងៃទី ៣០ តុលា ២០១៥ នៅសាលមហោស្រព
- ចូលរួមប្រជុំសាមញ្ញគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមាររបស់ក្រុមប្រឹក្សាខេត្ត ថ្ងៃទី ០៥ វិច្ឆិកា ២០១៥ សាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមទិវាបុណ្យឯករាជ្យជាតិ ០៩ វិច្ឆិកា ២០១៥ នៅថ្ងៃទី ០៩ វិច្ឆិកា ២០១៥ នៅសាលមហោស្របខេត្ត
- ចូលរួមសិក្ខាសាលា ស្តីពី ការផ្សព្វផ្សាយគោលនយោបាយ និងឯកសារគតិយុត្តិពាក់ព័ន្ធការងាររៀបចំដែនដីដល់ប្រជាពលរដ្ឋថ្នាក់ក្រោមជាតិ ថ្ងៃទី១៦ វិច្ឆិកា ២០១៥ នៅសាលមហោស្រព
- ចូលរួមប្រជុំណែនាំស្តីពីការរៀបចំបច្ចុប្បន្នភាពគម្រោងវិនិយោគ របស់កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តក្រចេះ ១៣ វិច្ឆិកា ២០១៥ នៅមន្ទីរផែនការខេត្តក្រចេះ
- សំណើនិងដំណោះស្រាយនៃវេទិការសាធារណៈប្រចាំស្រុកឆ្លូង នៅសាលាខេត្តក្រចេះ ថ្ងៃទី១៩វិច្ឆិកា ២០១៥
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងទិវាលាងសម្អាតដៃ ថ្ងៃទី២៨ វិច្ឆិកា ២០១៥ នៅវត្តបុសលាវ ។

## 3. <u>សកម្មភាពតាមការិយាល័យ</u>÷

### 3.1. <u>ការិយាល័យរដ្ឋបាល និងបុគ្គលិក</u>÷

ក. <u>ផ្នែកការងារលិខិតចូល</u> ÷ សរុបចំនួន៦៨៩លេខ ក្នុងនោះមានៈ

- លិខិតរបស់រាជរដ្ឋាភិបាល ចំនួន ៣៩ លេខ
- លិខិតរបស់ក្រសួងសាម៉ី ចំនួន ៩៤ លេខ
- លិខិតក្រសួងនានា ចំនួន ៧៩ លេខ
- លិខិតផ្សេងៗក្នុងខេត្ត ចំនួន ៤៧៧ លេខ

ខ. <u>ផ្នែកការងារលិខិតចេញ</u> សរុបចំនួន ៣២៩ លេខ ក្នុងនោះមាន÷

- លិខិតទៅនាយកដ្ឋាន និងក្រសួង ចំនួន ៩៩លេខ
- លិខិតផ្សេងៗទូទៅ ក្នុងខេត្ត ចំនួន ២៣០ លេខ

គ. <u>លិខិតឧទ្ទេសនាម</u>÷ សរុប ចំនួន ៣៣ លេខ

ឃ. <u>ផ្នែកការងារលិខិតបញ្ជាបេសកកម្ម</u>÷ សរុបចំនួន ២៣៧ លេខ

- ធ្វើសំណើសុំលិខិតបញ្ជាបេសកម្មលោកប្រធានមន្ទីរ ពី **ឯកឧត្តម អភិបាលខេត្ត** ចំនួន ២៤ លេខ
- ចេញលិខិតបញ្ជាបេសកកម្មជូនមន្ត្រី ចំនួន ២១៣ លេខ

ង. ផ្នែកបញ្ជីវត្តមាន÷ ពិនិត្យការចុះបញ្ជីវត្តមានប្រចាំថ្ងៃ ។

3.2. **ការិយាល័យផ្លូវជនបទ**÷

**សកម្មភាពការងារ**

- បានរៀបចំគម្រោង ដើម្បីសុំការអនុម័តសម្រាប់ ផែនការឆ្នាំ២០១៥ ចំនួន ៣គម្រោង÷
  - ចុះសិក្សាផ្លូវជួសជុល ភូមិខ្សាត់ទៅស្ទឹងទ្រ ប្រវែង ៦.៨០ គម ស្ថិតនៅឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ ដើម្បីត្រៀមធ្វើការជួសជុល
  - ចុះសិក្សាផ្លូវថែទាំជាលក្ខណៈខួប ភូមិសំរ៉ងទៅភូមិចឹង ប្រវែង ៨.០០ គម ស្ថិតនៅឃុំឃ្សឹម និងភូមិក្បាលស្នួល-ភូមិស្នួលកើត ប្រវែង ៤.០០ គម ស្ថិតនៅឃុំស្នួល ស្រុកស្នួល
  - ចុះសិក្សាផ្លូវថែទាំជាលក្ខណៈប្រចាំ ប្រវែង ២៩.៩០ គម ស្ថិតនៅភូមិវាលកន្សែង ភូមិប្រម៉ា ឃុំកំពង់ដំរី ស្រុកឆ្លូង ។
- ការងារមន្ទីរបានចូលរួមជាមួយនាយកដ្ឋានផ្លូវលំជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ ចុះសិក្សាស្ពាន នៅភូមិប្រម៉ា ឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ ទៅភូមិកំពាន់ ឃុំកំពាន់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ (តាមសំណូមពរវេទិការសាធារណៈ នៅភូមិប្រម៉ា) ។
- ចុះស្រង់ទិន្នន័យផ្លូវតាមប្រព័ន្ធ GPS បានចំនួន ១៣ ខ្សែ ប្រវែង ៤១.៩៨ គម ស្ថិតនៅស្រុកស្នួល ស្រុកព្រែកប្រសព្វ ស្រុកឆ្លូង និងស្រុកចិត្របុរី ។
- ចូលរួមពិនិត្យ និងសិក្សាផលប៉ះពាល់ដីរបស់ប្រជាពលរដ្ឋ នៅលើទីតាំងស្នើសុំផ្លូវចូលក្នុងក្រុម ហ៊ុន ស៊ី និងវី គ្រុប ស្ថិតនៅឃុំរលួសមានជ័យ ស្រុកសំបូរ ។
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ និងបូកសរុបលទ្ធផលការងាររៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវជនបទ ឆ្នាំ ២០១៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ។
- បញ្ជាក់បច្ចេកទេសគម្រោងមូលនិធិឃុំ សង្កាត់ ស្រុក ក្រុង ឆ្នាំ២០១៥ របស់សាលាខេត្ត ទីចាត់ការ ផែនការ និងវិនិយោគ បានចំនួន ៣៥ គម្រោង ។
- ចុះស្រង់ទិន្នន័យយានដ្ឋានរថយន្តកែច្នៃដឹកទំនិញធុនធ្ងន់ និងថតរូបយានដ្ឋានរថយន្ត ស្រុកឆ្លូង ស្រុកចិត្របុរី ស្រុកស្នួល និងក្រុងក្រចេះ បាន ២លើក ។
- ការងារធ្វើបច្ចុប្បន្នភាពផ្លូវ បានចំនួន ២២ ខ្សែ ប្រវែង ៤១៨.៧០ គម ស្ថិតនៅ ស្រុកចិត្របុរី ស្រុកសំបូរ ស្រុកស្នួល ស្រុកព្រែកប្រសព្វ ស្រុកឆ្លូង និងក្រុងក្រចេះ ។
- ចុះពិនិត្យទីតាំងគម្រោងផ្លូវថែទាំជាលក្ខណៈខួបឆ្នាំ ២០១៥ ស្ថិតនៅឃុំឃ្សឹម ឃុំស្នួល ស្រុកស្នួល ជាមួយក្រុមការងារអន្តរក្រសួង (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ។
- ចុះពិនិត្យការងារជួសជុលផ្លូវថែទាំលក្ខណៈខួប សោប-ស្រែងៀត ប្រវែង ១១.៧០ គម ស្ថិតនៅ ឃុំសោប ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ បានចំនួន ១៣ លើក ។

- ចុះពិនិត្យការងារជួសជុលផ្លូវថែទាំលក្ខណៈខួប វឌ្ឍនៈ - យាវ ប្រវែង ៩.៦០ គម ស្ថិតនៅ ឃុំវឌ្ឍនៈ ឃុំសំបូរ ឃុំកំពង់ចាម ស្រុកសំបូរបាន ៩ លើក ។
- ចុះពិនិត្យការងារវាយតម្លៃ ជាមួយគណៈកម្មាធិការអន្តរក្រសួង មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីបញ្ចប់សុពលភាពផ្លូវ អូរព្រះទៅខ្សាច់លាវ ប្រវែង ១០.០០ គម ស្ថិត នៅឃុំអូរគ្រៀង ស្រុកសំបូរ ។
- ប្រធានមន្ទីរ និងក្រុមការងារផ្លូវជនបទមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត គណៈកម្មាធិការលទ្ធកម្មខេត្ត ក្រុម ការងារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះពិនិត្យការងារវាយតម្លៃបញ្ចប់សុពលភាពផ្លូវ ឈ្មៃ-ស្រែទ្រៀក ប្រវែង ១៩.២០គម ជូនក្រុមហ៊ុន ស្ថិតនៅឃុំឆ្លូង ឃុំដីរីផុង ស្រុកឆ្លូង ។
- ប្រធានមន្ទីរ និងជាប្រធាន PIU និងក្រុមការងារខេត្តRIP-III អង្គភាពគ្រប់គ្រង PMU-RIPIII និងក្រុមការងារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះពិនិត្យការងារនិងវាយតម្លៃប្រគល់-ទទួលជួសជុលផ្លូវ ថែទាំជាលក្ខណៈខួប វឌ្ឍនៈ - យាវ ប្រវែង ៩.៦០ គម ស្ថិតនៅឃុំវឌ្ឍនៈ ឃុំសំបូរ ឃុំកំពង់ចាម ស្រុកសំបូរ និងជួសជុលផ្លូវថែទាំជាលក្ខណៈខួប សោប-ស្រែវៀត ប្រវែង ១១.៧០ គម ស្ថិតនៅ ឃុំសោប ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ ។
- ប្រធានមន្ទីរ និងក្រុមការងារការិយាល័យផ្លូវជនបទ នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ចុះពិនិត្យការងារ ជួសជុលស្ពានឈើ ០១ កន្លែង ប្រវែង ៣០ ម៉ែត្រ រអិលស្រុតសសរគ្រឹះ ស្ថិតនៅភូមិកោះខ្មែរ ឃុំអូរគ្រៀង ស្រុកសំបូរ ។
- ចុះពិនិត្យការងារជួសជុលថែទាំជាលក្ខណៈប្រចាំ ផ្លូវស្រែទ្រៀក-វាលកន្សែង ប្រវែង ៦.៣០ គម ស្ថិតនៅឃុំដីរីផុង ស្រុកឆ្លូង និងផ្លូវរលៀក-ប្រម៉ា ប្រវែង ១០.៨០ គម ស្ថិតនៅឃុំកំពង់ដីរី ស្រុកឆ្លូង បានចំនួន ៨លើក ។
- ក្រុមការងារអន្តរក្រសួង រួមមាន តំណាងក្រសួងអភិវឌ្ឍន៍ជនបទ និងតំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បានចុះត្រួតពិនិត្យស្ថានភាពជាក់ស្តែងនៃការខូចខាត របស់ផ្លូវចំនួន ០១ ខ្សែ ប្រវែង ២.៧០ គម ស្ថិតនៅភូមិបុកទឹក ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ ។
- ចុះពិនិត្យស្ថានភាពទឹកជំនន់តាមព្រែកឆ្លូង ដែលបាននាំសម្រាស់ឫស្សី មកជាប់ហ៊្មឹងសសរគ្រឹះស្ពាន កំពង់ស្រែ ឃុំឆ្លូង ស្រុកឆ្លូង ចំនួន ៤ លើក ។
- ចុះពិនិត្យការងារជួសជុលបន្ទាន់ផ្លូវ បុកទឹក-ព្រែកប្រាំង ប្រវែង ២.៧០ គម ឃុំព្រែកប្រសព្វ ស្រុក ព្រែកប្រសព្វ បានចំនួន ៥ លើក ។
- ចុះពិនិត្យការងារជួសជុលផ្លូវថែទាំជាលក្ខណៈខួប ផ្លូវសំរ៉ង-ចឹង ប្រវែង ៨.០០ គម ស្ថិត នៅឃុំឃ្សឹម ស្រុកស្នួល និងផ្លូវក្បាលល្នួល-ល្នួលកើត ប្រវែង ៤.០០ គម ស្ថិតនៅ ឃុំស្នួល ស្រុកស្នួល បានចំនួន ០៨ លើក ។
- ចុះពិនិត្យការងារជួសជុលផ្លូវភូមិខ្សាត់ទៅភូមិស្ទឹងទ្រ ប្រវែង ៦.៨០ គម ស្ថិតនៅឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ ៨លើក ។

- ក្រុមការងារក្រសួង និងក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បានចុះពិនិត្យនិងវាយ តម្លៃការងារបញ្ចប់ជួសជុលបន្ទាន់ផ្លូវបុកទឹក-ព្រែកប្រាំងប្រវែង ២.៧០ គម ស្ថិតនៅឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ ។
- គណៈកម្មាធិការអន្តរៈក្រសួង ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះពិនិត្យនិងវាយតម្លៃប្រគល់ -ទទួលផ្លូវ ២ខ្សែប្រវែង ១២.០០ គម និងសាសង់លូទោលកាត់ផ្លូវចំនួន ០៤ កន្លែង បញ្ចប់ការងារជួសជុល ១០០% ស្ថិតនៅ ឃុំឃ្សឹម ឃុំស្នួល ស្រុកស្នួល ។
- ក្រុមការងារក្រសួង និងក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បានចុះពិនិត្យនិងវាយតម្លៃការងារបញ្ចប់ជួសជុលបន្ទាន់ផ្លូវ ចំនួន ០៣ខ្សែ ប្រវែង ៣.២០ គម ស្ថិតនៅ និងឃុំថ្មគ្រែ ឃុំសំបុក ស្រុកចិត្របុរី ។

__លទ្ធផលការងារ__

- ការងារជួសជុលផ្លូវថែទាំលក្ខណៈខួប ចំនួន ០៤ ខ្សែ ប្រវែង ៣៣.៣០ គម ស្ថិតនៅឃុំវឌ្ឍនៈ ឃុំសំបូរ ឃុំកំពង់ចាម ស្រុកសំបូរ, ឃុំសោប ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ, ឃុំឃ្សឹម ឃុំស្នួល ស្រុកស្នួល លទ្ធផលសម្រេចបាន ១០០% ។
- ការងារជួសជុលថែទាំជាលក្ខណៈប្រចាំ ចំនួន ០២ខ្សែ ប្រវែង ១៧.១០ គម ស្ថិតនៅឃុំដំរីផុង និងឃុំកំពង់ដំរី ស្រុកឆ្លូង លទ្ធផលសម្រេចបាន ១០០ % ។
- ការងារជួសជុលផ្លូវ ភូមិខ្សាត់ទៅភូមិស្ទឹងទ្រ ប្រវែង ៦ .៨០ គម ស្ថិតនៅឃុំតាម៉ៅ ស្រុកព្រែក ប្រសព្វ លទ្ធផលសម្រេចបាន ១០០ % ។
- ការងារជួសជុលបន្ទាន់ផ្លូវ ចំនួន ០៣ខ្សែ ប្រវែង៥.៩០ គម ស្ថិតនៅឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ និងឃុំថ្មគ្រែ ឃុំសំបុក ស្រុកចិត្របុរី លទ្ធផលសម្រេចបាន ១០០ % ។
- ការងារធ្វើបច្ចុប្បន្នភាពផ្លូវ បានចំនួន ២២ខ្សែ ប្រវែង ៤១៨.៧០ គមស្ថិតនៅ ស្រុកចិត្របុរី ស្រុកសំបូរ ស្រុកស្នួល ស្រុកព្រែកប្រសព្វ ស្រុកឆ្លូង និងក្រុងក្រចេះ លទ្ធផលសម្រេចបាន ១០០ % ។
- ការងារស្រង់ទិន្នន័យផ្លូវបានចំនួន ១៣ ខ្សែ ប្រវែង ៤១.៩៨ គម ស្ថិតនៅ ស្រុកស្នួល ស្រុកព្រែកប្រសព្វ ស្រុកឆ្លូង និងស្រុកចិត្របុរី លទ្ធផលសម្រេចបាន ១០០ % ។
- គណៈកម្មាធិការអន្តរៈក្រសួង ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះពិនិត្យ និងវាយតម្លៃប្រគល់ -ទទួលផ្លូវ ០២ ខ្សែ ប្រវែង ១២.០០ គម និងសាសង់លូទោលកាត់ផ្លូវ ចំនួន ០៤ កន្លែង បញ្ចប់ការងារជួសជុល ១០០% ស្ថិតនៅ ឃុំឃ្សឹម ឃុំស្នួល ស្រុកស្នួល ។
- ការងារជួសជុលស្ពានឈើ ០១កន្លែង ប្រវែង ៣០ ម៉ែត្រ រអិលស្រុតសសរគ្រឹះ ស្ថិតនៅភូមិកោះខ្មែរ ឃុំអូរគ្រៀង លទ្ធផលសម្រេចបាន ១០០ % ។
- ប្រធានមន្ទីរ និងជាប្រធាន PIU និងក្រុមការងារខេត្ត RIP-III អង្គភាពគ្រប់គ្រង PMU-RIPIII និងក្រុមការងារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះពិនិត្យការងារនិងវាយតម្លៃប្រគល់-ទទួលជួសជុលផ្លូវថែទាំជាលក្ខណៈខួប វឌ្ឍនៈ - យាវ ប្រវែង ៩.៦០ គម ស្ថិតនៅឃុំវឌ្ឍនៈ ឃុំសំបូរ ឃុំកំពង់ចាម

ស្រុកសំបូរ និងជួសជុលផ្លូវថែទាំជាលក្ខណៈខួប សោប-ស្រែងៀត ប្រវែង ១១.៧០ គ.ម ស្ថិតនៅឃុំសោប ឃុំព្រែកប្រសព្វស្រុកព្រែកប្រសព្វសម្រេចបាន ១០០% ។

- មន្ទីរសហការជាមួយអាជ្ញាធរស្រុកឆ្លូង ចំនួន ០៣ លើក ដើម្បីទាញសម្រាស់ឫស្សី ជាប់នឹងសសរគ្រឹះស្ពាន ដោយចំណាយថវិការអស់ ១,៥០០,០០០ រៀល ក្នុងនោះមន្ទីរជួយចេញ ៧៥០,០០០ រៀល ។

### 3.3. ការិយាល័យផ្គត់ផ្គង់ទឹកជនបទ÷

- ចុះពិនិត្យអណ្តូងស្នប់ខូចចំនួន ២៩ អណ្តូង ក្នុងនោះស្រុកស្នួល ១៥ អណ្តូង ស្រុកចិត្របុរី ១២ អណ្តូង ស្រុកព្រែកប្រសព្វ ០១ អណ្តូង សាលាបឋមសិក្សាកោះទ្រង់ ០១ អណ្តូង (តាមសំណូមពរវេទិកាសាធារណៈ នៅសង្កាត់ កោះទ្រង់ ក្រុងក្រចេះ) ។
- ចុះជួសជុលអណ្តូងលូ ស្រុកព្រែកប្រសព្វ ២១ អណ្តូង ។
- ស្តារស្រះសហគមន៍ស្រុកព្រែកប្រសព្វ ០១ ស្រះ ។
- ធ្វើយុទ្ធនាការផ្សព្វផ្សាយអំពីការបន្សុទ្ធទឹក និងការទុកដាក់ទឹកអោយមានសុវត្ថិភាពតាមគ្រួសារ នៅភូមិប្រឡាយទ្រៀក ១២០ គ្រួសារ និងភូមិក្រូច ១២០ គ្រួសារ ឃុំដំរីផុង ស្រុកឆ្លូង ។
- ចុះពិនិត្យការសាងសង់ខឿនអណ្តូងស្នប់ នៅភូមិប្រម៉ា ឃុំដំរីផុង ទទួលបាន ៧0% ។
- ចុះវាយតម្លៃការបន្សុទ្ធទឹក និងការទុកដាក់ទឹកអោយមានសុវត្ថិភាពតាមគ្រួសារចំនួន ១០០ គ្រួសារ ភូមិក្រូច និង ភូមិប្រឡាយទ្រៀក ឃុំដំរីផុង ស្រុកឆ្លូង (ឃើញថាមានការកែប្រែ) ។
- ចុះបិទកម្មវិធីការបន្សុទ្ធទឹក និងការទុកដាក់ទឹកអោយមានសុវត្ថិភាពតាមគ្រួសារតាមរយៈសំនួរ ចម្លើយ និងមានរង្វាន់លើកទឹកចិត្តជាសម្ភារ កំសៀវទឹក ចំនួន ៦០ កំសៀវ ដល់ភូមិក្រូច ៣០ កំសៀវ និង ភូមិប្រឡាយទ្រៀក ៣០ កំសៀវ ឃុំដំរីផុង ស្រុកឆ្លូង ។
- ចុះប្រមូលទិន្នន័យ និងធ្វើបច្ចុប្បភាពអណ្តូងស្នប់ ៥៨ អណ្តូង ឃុំស្វាយជ្រះ ស្រុកស្នួល និង ២២ អណ្តូង ឃុំកំពង់ដំរី ស្រុកឆ្លូង ។
- ចុះត្រួតពិនិត្យ និងវាយតំលៃអណ្តូងស្នប់របស់អង្គការ PADEK កំពុងសាងសង់នៅឃុំដំរីផុង បានចំនួន ០៣ អណ្តូង ។
- ចុះជួសជុលអណ្តូងស្នប់បានចំនួន ១១៧ អណ្តូង
    - ស្រុកស្នួល ៥៩ អណ្តូង ស្ថិតនៅឃុំ២ធ្នូ ២៥ អណ្តូង ឃុំស្រែចារ ៣៤ អណ្តូង
    - ស្រុកចិត្របុរី ២១ អណ្តូង ស្ថិតនៅឃុំកន្ទួត ០៥ អណ្តូង ឃុំដារ ០១ អណ្តូង ដីសម្បទានកំពី ០៥ អណ្តូង ឃុំគោលាប់ ០៥អណ្តូង ឃុំចង្រ្កង់ ០៤ អណ្តូង ស្រុកឆ្លូង ០៣ អណ្តូង ស្ថិតនៅឃុំដំរីផុង ០៣ អណ្តូង
    - ក្រុងក្រចេះ ០៤ អណ្តូង ស្ថិតនៅសង្កាត់ក្រគរ ០៤ អណ្តូង

- ស្រុកសំបូរ ២៣ អណ្តូង ស្ថិតនៅឃុំសំបូរ ០៥ អណ្តូង ឃុំកោះខ្ញែរ ០១ អណ្តូង ឃុំស្រែជិះ ១៣ អណ្តូង រលួសមានជ័យ ០៤ អណ្តូង
- ស្រុកព្រែកប្រសព្វ០៨ អណ្តូង ឃុំជ្រោយបន្ទាយ ។

- សាងសង់អណ្តូងស្នប់ថ្មីបានចំនួន ១៣ អណ្តូង នៅក្នុងស្រុកចិត្របុរី ៨ អណ្តូង ស្រុកឆ្លូង ០១ អណ្តូង ស្រុកសំបូរ ០៣ អណ្តូង ក្រុងក្រចេះ ០១ អណ្តូង ។

3.4. **<u>ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ÷</u>** (គ្មានសកម្មភាព)

3.5. **<u>ការិយាល័យអភិវឌ្ឍន៍សហគមន៍÷</u>**

- រៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០១៥ និងរៀបចំផែនការសកម្មភាព និងផែន ការចំណាយសម្រាប់ឆ្នាំ ២០១៦ ។
- សម្របសម្រួលបង្កើតគ.អ.ភ និងបណ្តុះបណ្តាលស្តីពីតួនាទី ភារកិច្ច របស់គ.អ.ភ នៅភូមិសម្បទានកាកុត ភូមិកំពី និងភូមិសម្បទានកំពី ឃុំសំបុក ស្រុកចិត្របុរី ចំនួនគ.អ.ភ សរុប ៣៣ នាក់ ក្នុងនោះស្ត្រីមាន ១៣ នាក់ ។
- បណ្តុះបណ្តាលគ.អ.ភ ស្តីពី ការធ្វើផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ ចំនួន ១២ វគ្គ នៅ ភូមិ ចំនួន ៨៤ ភូមិ ស្មើនឹង ២៣ឃុំ/សង្កាត់ ក្នុងស្រុកចំនួន៤ និងក្រុង០១ ដែលមានអ្នកចូលរួម សរុបចំនួន ៤២០នាក់ ក្នុងនោះស្ត្រីមាន ១០៨ នាក់ ។
- ចុះបណ្តុះបណ្តាលគ.អ.ភ និងកសិករ ស្តីពី÷ សញ្ញាណសន្តិសុខស្បៀងស្នូនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្តិ៍ នៅភូមិសំបូរសែនជ័យ និងភូមិវត្ត ក្នុងឃុំស្វាយជ្រះ ស្រុកស្នួល ដែលមានអ្នកចូលរួមសរុប ៤០នាក់ ក្នុងនោះស្ត្រីមានចំនួន ១២នាក់ ។
- សិក្សាពីតម្រូវការនានា ដើម្បីរៀបចំគម្រោងសន្តិសុខស្បៀង នៅភូមិចំនួន ០៣ គឺភូមិថ្មល់ ភូមិវត្ត និងភូមិសំបូរសែនជ័យ នៃឃុំស្វាយជ្រះ ស្រុកស្នួល ។
- ចុះតាមដាន និងត្រួតពិនិត្យ សមាសភាព និងសកម្មភាព គ.អ.ភ នៅឃុំស្វាយជ្រះ ស្រុកស្នួល បានចំនួន ០៨ ភូមិ ។
- ចុះធ្វើបច្ចុប្បន្នភាពសមាសភាព គ.អ.ភ នៅឃុំឃ្សឹម បាន០៨ភូមិ ក្នុងស្រុកស្នួល ។

❖ **<u>ការងារសហការជាមួយអង្គការឆាលហ្វានកម្ពុជាប្រចាំខេត្តក្រចេះ</u>**

- ចុះបណ្តុះបណ្តាល គ.អ.ភ ស្តីពី និរន្តរភាពនៃការអភិវឌ្ឍសហគមន៍ នៅស្រុកឆ្លូង ដោយមានការសហការរវាងមន្ទីរអភិវឌ្ឍន៍ជនបទ និងអង្គការឆាលហ្វានកម្ពុជាប្រចាំខេត្តក្រចេះ បានចំនួន ០៤ វគ្គ ស្មើនឹង០៤ឃុំ (ឃុំហាន់ជ័យ ឃុំពង្រ ឃុំខ្សាច់អណ្តែត និងឃុំដំរីផុង) ស្មើនឹង ១៨ ភូមិ និងមានអ្នកចូលរួម ១១៩ នាក់ ស្ត្រី ៥៩ នាក់ ។

- ចុះសហការជាមួយអង្គការឆាលហ្វានកម្ពុជា ក្នុងការត្រួតពិនិត្យតាមដានសកម្មភាព គ.អ.ភ នៅស្រុកឆ្លូង បានចំនួន ០៨ ឃុំ ស្មើនឹង ៤០ ភូមិ ដែលមានអ្នកចូលរួមចំនួនសរុប ៣៧២ នាក់ ស្ត្រី ១៦២ នាក់ ។
- ចុះរៀបចំរចនាសម្ព័ន្ធ គ.អ.ភ ឡើងវិញ និងពង្រឹង គ.អ.ភ ពីភាពទទួលខុសត្រូវរបស់ គ.អ.ភ បានចំនួន ២០ ភូមិ ០៤ ឃុំ (ឃុំកំពង់ដំរី ឃុំដំរីផុង ឃុំព្រែកសាម៉ាន់ និងឃុំកញ្ជរ) ក្នុងស្រុកឆ្លូង មានអ្នកចូលរួមចំនួនសរុប ១៦០នាក់ ស្ត្រី ៦៥នាក់ ។
- ចុះបណ្តុះបណ្តាលគ.អ.ភនៅស្រុកឆ្លូង ស្តីពី ការដោះស្រាយទំនាស់តាមសហគមន៍ចំនួន ១០ វគ្គ ស្មើនឹង ៤០ ភូមិ ស្មើនឹង ០៨ ឃុំ និងមាន គ.អ.ភ ចូលរួមចំនួន ៣៤២ នាក់ ក្នុងនោះស្ត្រី ១៦១ នាក់ ។
- ចុះបណ្តុះបណ្តាលគ.អ.ភ ស្តីពី ការប្រែប្រួលអាកាសធាតុបន្សាំ និងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ នៅស្រុកឆ្លូង ចំនួន ១០ វគ្គ ស្មើ នឹង ៤០ ភូមិ ស្មើនឹង ០៨ ឃុំ និងអ្នកចូលរួមសរុប ៣២២ នាក់ ក្នុងនោះស្ត្រី ចំនួន ១៦២ នាក់ ។
- ចុះបណ្តុះបណ្តាលយុវជន ស្តីពី ការប្រែប្រួលអាកាសធាតុបន្សាំ និងការកាត់បន្ថយគ្រោះភ័យ នៃគ្រោះមហន្តរាយ នៅស្រុកឆ្លូង ចំនួន ០២ វគ្គ ដែល មានអ្នកចូលរួម ៨៦ នាក់ ក្នុងនោះស្ត្រីចំនួន ៣៤ នាក់ ។

3.6. <u>**ការិយាល័យជនជាតិដើមភាគតិច**</u>÷

- ចូលរួមសហការណ៍ជាមួយ មន្ទីរដែនដី និងនគរោបនីយកម្មសំណង់ នៅសហគមន៍ជនជាតិដើមភាគតិច គឺឃុំស្រែជិះ និងឃុំរលួសមានជ័យ ស្រុកសំបូរ ។
- ចូលរួមសិក្ខាសាលាកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិស្តីពី សេចក្តីព្រៀងយុទ្ធសាស្ត្រ (រេដប៊ូក) ជាតិលើកទី ០៤ ខេត្តក្រចេះ សណ្ឋាគារ លី ជី ។

3.7. <u>**ការិយាល័យថែទាំសុខភាពជនបទ**</u>÷

- ប្រជុំផ្សព្វផ្សាយស្តីពីការលើកកម្ពស់អនាម័យជនបទថ្នាក់ឃុំ ស្ថិតនៅឃុំកោះខ្ញែរ ស្រុកសំបូរ មានអ្នកចូលរួម ១១ នាក់ ស្ត្រី ០២ នាក់ ។
- ប្រជុំផ្សព្វផ្សាយស្តីពីការលើកកម្ពស់អនាម័យសហគមន៍ជនបទ អ្នកចូលរួម ១៥៧នាក់ស្ត្រី ៨២ នាក់ ក្នុងឃុំខ្សាច់អណ្តែត ស្រុកឆ្លូង ។
- ចុះផ្សព្វផ្សាយ និងបំផុសប្រជាជនឲ្យយល់ដឹងអំពីអនាម័យ ហើយស្ម័គ្រចិត្តសាងសង់បង្គន់ដោយខ្លួនឯង បានចំនួន ១៦៤១ បង្គន់÷ ស្រុកព្រែកប្រសព្វ ៥៧៨បង្គន់ ស្រុកសំបូរ ៧១បង្គន់ ស្រុកឆ្លូង ២៩៣ បង្គន់ ស្រុកចិត្របុរី ១៨២ បង្គន់ ស្នួល ៥១៩ បង្គន់ ។
- យុទ្ធនាការផ្សព្វផ្សាយអនាម័យតាមសាលាស្តីពីការលាងសម្អាតដៃ និងរបៀបប្រើប្រាស់បង្គន់÷
    - សាលាបឋមសិក្សាប្រហួត ឃុំដំរីផុង មានសិស្សចូលរួម ១៥៣ នាក់ ស្រី៩៨ នាក់
    - សាលាបឋមសិក្សាមានដំរីផុង ឃុំដំរីផុងសិស្ស ចូលរួម ២៩៩ នាក់ ស្រី ១៤៩ នាក់
    - សាលាបឋមសិក្សាព្រៃគោ ឃុំដំរីផុង មានសិស្សចូលរួម ២៩៨ នាក់ ស្រី ១៦២ នាក់

- សាលាបឋមសិក្សាបឹងកៀប ឃុំដីរីផុង មានសិស្ស ចូលរួម ១៤៣ នាក់ ស្រី ៨៦ នាក់
- សាលាបឋមសិក្សាវាលកន្សែង ឃុំដីរីផុង សិស្សចូលរួម ២៦០ នាក់ ស្រី ១៧៥ នាក់
- សាលាបឋមសិក្សាប្រម៉ា ឃុំដីរីផុង មានសិស្សចូលរួម ២២០ នាក់ ស្រី ១៣៩ នាក់
- សាលាបឋមសិក្សាព្រែកសំរោង ឃុំខ្សាច់អណ្តែត សិស្សចូលរួម ២៨៨នាក់ ស្រី១៣២ នាក់
- សាលាបឋមសិក្សាភូមិថ្មី ឃុំខ្សាច់អណ្តែត សិស្សចូលរួម ២៦១ នាក់ ស្រី ១៥៣ នាក់
- សាលាបឋមសិក្សាឆក់កន្ទោង មានសិស្ស ចូលរួម ២៣៤ នាក់ ស្រី ១៤៣ នាក់
- សាលាបឋមសិក្សាក្រូច មានសិស្សចូលរួម ២៦១ នាក់ ស្រី ១៥៦ នាក់
- សាលាបឋមសិក្សាប្រឡាយទ្រៀក មានសិស្សចូលរួម ១៥៣ នាក់ ស្រី ៧៦ នាក់ ។

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី ការកសាងផែនការសកម្មភាពជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ការងារផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទ ២០១៤-២០១៥ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ មានអ្នកចូលរួម ៤៨ នាក់ ស្ត្រី ០៨ នាក់ ។
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី៣ ស្តីពីការបន្ស៊ីផែនការ សកម្មភាពជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ការងារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ២០១៤-២០១៨ នៅសណ្ឋាគារអង្គរសិនធីរី ក្រុងសៀមរាប មានអ្នកចូលរួម ៥២ នាក់ ស្ត្រី ០៨ នាក់ ។
- ចុះផ្សព្វផ្សាយសកម្មភាពស្តីពី ការលើកកម្ពស់អនាម័យតាមសហគមន៍ និងពង្រឹងបណ្តាញជនបង្គោលស្ម័គ្រចិត្តភូមិ ជ្រើសរើសអ្នកស្ម័គ្រចិត្តសាងសង់បង្គន់អនាម័យតាមគ្រួសារ÷
    - ស្រុកព្រែកប្រសព្វ ឃុំជ្រោយបន្ទាយមាន ០៤ ភូមិ មានអ្នកចូលរួមប្រជុំ ១១៣ នាក់ ស្ត្រី ៨៥ នាក់ កុមារ ២១ នាក់
    - ស្រុកសំបូរ ឃុំវឌ្ឍនៈ ០៤ភូមិ មានអ្នកចូលរួមប្រជុំ ១២២នាក់ ស្ត្រី ៨០ នាក់ កុមារ ១៩ នាក់ ។
- ចែកសម្ភារសាងសង់បង្គន់អនាម័យ តាមគ្រួសារនៅឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ បានចំនួន ១០០ សម្រាប់ ស្រុកសំបូរ ១៥០ សម្រាប់ ។

3.8. **<u>ការងារបណ្តុះបណ្តាលមន្ត្រីរាជការ</u>÷** មានចំនួន ២៥ លើក ។

## 4. <u>ទិសដៅបន្ត÷</u>

- ការងារថែទាំជាលក្ខណៈខួប មានចំនួន ០៤ ខ្សែ សរុបប្រវែង ៣០.៧០ គ.ម
- ការងារថែទាំជាលក្ខណៈប្រចាំ មានចំនួន ០២ ខ្សែ សរុបប្រវែង ៣១.៤០ គ.ម
- ការងារជួសជុលចំនួន ០១ ខ្សែ មានប្រវែងសរុបចំនួន ៧.២០ ម៉ែត្រ
- ការងារជួសជុលបន្ទាន់ចំនួន ០២ ខ្សែមានប្រវែងសរុបចំនួន ៦.១០ គ.ម
- ការងារផ្លូវកៅស៊ូ ០១ ខ្សែ ប្រវែង ១២.០០ គ.ម
- ការងារសាងសង់ផ្លូវថ្មីក្រួសក្រហម ០២ ខ្សែប្រវែង ២៥.៥០ គ.ម

- ការងារជុសជុលអណ្ដូងស្នប់ ៣៥ អណ្ដូង
- ការងារជុសជុលអណ្ដូងលូ ២៥ អណ្ដូង
- ការងារសាងសង់អណ្ដូងថ្មីលូ ១២ អណ្ដូង
- ការងារស្ដារស្រះសហគមន៍
- ការងារសាងសង់អាងត្រងទឹកភ្លៀង ចំណុះ៤០០០ លីត្រ ០៧ អាង
- ការងារសាងសង់អាងត្រងទឹកភ្លៀង ចំណុះ ៣៥ ម៉ែត្រគ្រីប ០២ អាង
- ការងារសាងសង់ប្រព័ន្ធចែកចាយទឹក ០១
- តាមដានសកម្មភាពគ.អ.ភ ឡើងវិញ
- បណ្ដុះបណ្ដាលគ.អ.ភ ស្ដីពីការធ្វើផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ
- បណ្ដុះបណ្ដាលប្រជាពលរដ្ឋ និងគ.អ.ភ ស្ដីពីសន្តិសុខស្បៀង
- គម្រោងអភិវឌ្ឍន៍ភូមិចម្រុះ
- បណ្ដុះបណ្ដាលដល់គ្រូបង្គោលក្រុមប្រឹក្សាឃុំស្ដីពីការលើកកម្ពស់អនាម័យសុខភាពជនបទ
- បំផុស និងផ្សព្វផ្សាយប្រជាជន ឲ្យសាងសង់បង្គន់អនាម័យទាំង ០៥ ស្រុក
- តាមដាន និងត្រួតពិនិត្យការសាងសង់បង្គន់អនាម័យទាំង ០៥ ស្រុក
- ធ្វើបច្ចុប្បន្នភាពទិន្នន័យបង្គន់អនាម័យក្នុងខេត្តក្រចេះ
- រៀបចំបង្កើតសហគមន៍ជនជាតិដើមភាគតិច ដោយសហការជាមួយអង្គការដៃគូរ ៕

**ប្រធានមន្ទីរ**